- ជាលេខាធិការរបស់ក្រសួងក្នុងកិច្ចការសំរបសំរួលរាល់ការងារអាស៊ាន ជាមួយនឹងអគ្គនាយកដ្ឋានអាស៊ាននៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គភាពអាស៊ាននៃក្រសួងនានា
- ទំនាក់ទំនងជាមួយអង្គភាពនានា ដែលស្ថិតនៅក្រោមឱវាទក្រសួង ស្រង់បាននូវពត៌មានសំខាន់ៗ និង សំណូមពរដែលពាក់ព័ន្ធដល់ការងារអាស៊ាន ។
- ចូលរួមប្រជុំតាមកម្មវិធីកំណត់ប្រចាំឆ្នាំនៃអង្គការអាស៊ាន ដែលពាក់ព័ន្ធលើវិស័យការងារសង្គមកិច្ច និង អតីតយុទ្ធជន ។
- ផ្សព្វផ្សាយពត៌មានអំពីសកម្មភាពអាស៊ាន ជូនដល់មន្ត្រីរាជការនៅក្នុងក្រសួង ។
- លើគំរោងថវិកា ចំណាយប្រចាំឆ្នាំនីមួយៗ សំរាប់ការងារអាស៊ានរបស់ក្រសួង ។
- ធ្វើរបាយការណ៍អំពីសកម្មភាពការងារ ដែលពាក់ព័ន្ធនឹងកិច្ចការអាស៊ានទៅតាមរបបកំណត់ នៃអគ្គនាយកដ្ឋានអាស៊ានជាតិ ។

**ប្រការ ៣** : លោកប្រធានមន្ទីរលោកប្រធានអង្គភាពនានា ក្រោមឱវាទក្រសួងសង្គមកិច្ចការងារ មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**

* * *

## ៦—ឧស្ដីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ១—សេចក្ដីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៦

**សេចក្ដីសំរេចលេខ ១២៩ បន**

**ស្ដីពីការបង្កើតគណៈកម្មការត្រួតពិនិត្យតាមក្រុមហ៊ុនដែល**

**ធ្វើអាជីវកម្ម សេវា ប្រៃសណីយ៍ ក្នុងរាជធានីភ្នំពេញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការកែសំរួលរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦-២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើ ដោយច្បាប់ស្តីពីការបង្កើត ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញលិខិតលេខ ២៤៤៧ លសស ចុះថ្ងៃទី ០៤-៧-១៩៩៦ របស់ សាលាក្រុង ភ្នំពេញ
- បានឃើញលិខិតលេខ ៦១៨ បទ.ប ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ១៩៩៦ របស់នាយកដ្ឋានប្រៃសណីយ៍

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការចុះត្រួតពិនិត្យតាមក្រុមហ៊ុនដែលធ្វើអាជីវកម្ម សេវាប្រៃសណីយ៍ ក្នុងរាជ ធានីភ្នំពេញ មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១_លោក **ឡី សេង** | អនុប្រធានអធិការដ្ឋានក្តាប់រួមស្តីទី | ប្រធាន |
| ២_លោក **ញ៉ែម សារ៉ន** | តំណាងសាលាក្រុងភ្នំពេញ | អនុប្រធាន |
| ៣_លោក **ចា ស៊ីម** | អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ៤_លោក **កែវ សារិន** | ប្រធានការិយាល័យអាជីវកម្មប្រៃសណីយ៍ | លេខាធិការ |

**ប្រការ ២** : គណៈកម្មការមានភារកិច្ចប្រជុំពិភាក្សា និងចុះត្រួតពិនិត្យតាមបណ្តាក្រុមហ៊ុនដែលធ្វើអាជីវកម្មសេវា ប្រៃសណីយ៍ នៅក្នុងរាជធានីភ្នំពេញ ធ្វើយ៉ាងណាអោយមានលក្ខណៈល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៣** : គណៈកម្មការដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្ត តាមខ្លឹមសារនៃសេចក្តីសំរេចនេះ ។

**ប្រការ ៤** : សេចក្តីសំរេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការស្តីទី

ហត្ថលេខា និង ត្រា

**ស៊ុំ ម៉ានិត**